## ប្រយោជន៍អំពីគុណភាពខ្ពស់

### កម្មវិធីរៀននៅពេលអាយុតូច

កម្មវិធីរៀននៅពេលអាយុតូច និង កម្មវិធីរៀនផ្សេងៗ គឺផ្តល់ចំណេះគិតបានយ៉ាងជ្រៅជ្រះ និង បទពិសោធដ៏ល្អសំរាប់សិស្ស ដែលនឹងនាំមកលទ្ធផលជោគជ័យនៅសាលារៀន និង អ្វីជាបន្ថែមទៅទៀត ។

ការស្រាវជ្រាវបានបង្ហាញមកថា សិស្ស ដែលចូលរៀនក្នុងកម្មវិធីមានគុណភាពខ្ពស់តាំងពីអាយុតូចមកម្លេះ គឺច្រើនតែ:

- មានចិត្តរៀនជាមួយកិច្ចការកាន់តែលំបាកជាមួយមិត្តរួមថ្នាក់ ។
- ចូលរៀនថ្នាក់មត្តេយ្យ ដោយមានចំណេះចាំបាច់ជាស្រេចសំរាប់ងាយបំពេញកិច្ចការនៅក្នុងថ្នាក់ ។
- មានចំណេះកាន់តែស្ទាត់អំពីផ្នែកមេលេខ ។
- ទទួលការយល់ដឹងអំពីទំនាក់ទំនងរវាងផ្ទះ និង សាលារៀន - មានមាតាបិតារបស់ខ្លួនជាគ្រូបង្រៀនមុនគេ ។
- មិនសូវមានបញ្ហា ... រៀនធ្លាក់ថ្នាក់ រៀនក្នុងកម្មវិធីអប់រំពិសេស និង ជួបបញ្ហាផ្សេងៗទៀត ដូចជា: មានផ្ទៃពោះនៅវ័យជំទង់ និង គេចខ្លួនចោលពីសាលារៀន ។
- រៀនបានជោគជ័យទាំងផ្នែកអាន ប្រឡង និង ការបញ្ចប់ទទួលជាសញ្ញាប័ត្រស្របច្បាប់ ។



## ពត៌មានសំរាប់ទាក់ទង

**LBUSD Head Start**
1260 E. 33rd Street
Signal Hill, CA 90755
**562.426.814**

**Educare Los Angeles At Long Beach**
4840 Lemon Avenue
Long Beach, CA 90807
**562.422.6618**

**LBUSD Child Development Centers**
4400 Ladoga Ave.
Lakewood, CA 90713
**562.421.8210**

**LBUSD Buffum Total Learning Center**
2350 Ximeno Ave.
Long Beach, CA 90815
**562.494.4898**

**Long Beach Unified School District**
Office of the Deputy Superintendent of Schools
1515 Hughes Way
Long Beach CA 90810
**562.997.8328**

www.lbschools.net

# Early Learning Programs



LONG BEACH UNIFIED SCHOOL DISTRICT

## សារសំខាន់អំពី

### កម្មវិធីរៀននៅពេលអាយុតូច

តើអ្នកដឹងទេថា នៅពេលក្មេងចាប់ផ្តើមរៀនតាំងពីអាយុតូចមក គឺវានឹងជួយពង្រឹង សមត្ថភាពសំរាប់ការរៀនបន្តដល់កំរិតថ្នាក់កាន់តែខ្ពស់? ការស្រាវជ្រាវបានបង្ហាញ មកថា កម្មវិធីរៀននៅពេលអាយុតូចនឹងនាំមកប្រយោជន៍ច្រើនណាស់សំរាប់សិស្សពី ពេលមានកំណើតភ្លាមរហូតដល់អាយុ ប្រាំ ឆ្នាំ ។ គុណភាពខ្ពស់អំពីកម្មវិធីរៀននៅ ពេលអាយុតូច គឺមានជាគោលដៅស្របគ្នាដូចតទៅៈ បណ្តុះប្រាជ្ញា និង លើកទឹកចិត្ត សំរាប់សិស្ស តាមរយៈបង្កើតកម្មវិធីផ្សេងៗ ដើម្បីជួយបំរុងពួកគេចូលរៀននៅតាម សាលាបឋមសិក្សា ។

ក្រសួងអប់រំ ឌីស្រ្ទីគ Long Beach ផ្តល់ជាកម្មវិធីល្អៗទៅកាន់សិស្សអាយុ តូចស្របតាមក្បួនវិទ្យាសាស្រ្តស្រាវជ្រាវយ៉ាងស័ក្តសិទ្ធ ។

**ផ្នែកបណ្តុះតាមរយៈផ្លូវចិត្ត និង សង្គម** គឺសំខាន់សំរាប់សិស្សរៀនកាន់ភ្ជាប់អាកប្ប កិរិយា និង លក្ខណៈផ្សេងៗសំរាប់ការរស់នៅយ៉ាងចុះសំរុងក្នុងសង្គម និង ការរៀន បានយ៉ាងជោគជ័យនៅសាលារៀន ។

**ការរៀនបញ្ចូលគ្នា** ដែលរាប់ទាំងការយល់ដឹងត្រឹមត្រូវ ការលេងតាមរបៀប និង មេរៀនរៀបចំបង្ហាត់ដោយគ្រូ ដើម្បីនាំលទ្ធផលជោគជ័យមកកាន់សិស្ស ។

**សហការជាមួយក្រុមគ្រួសារ** ដែលនឹងជួយសិស្សតាមរយៈបង្កើតទំនាក់ទំនងយ៉ាង ប្រសប់ទៅវិញទៅមក រួមទាំងការលើកបង្ហាញអំពីអ្វីសិស្សកំពុងតែរៀន និង មធ្យោបាយបង្កើនភាពលូតលាស់ ។

**ផ្នែកបណ្តុះភាសា** គឺផ្តើមដោយការប្រើគំរូពីគ្រូបង្រៀន និង ការនិយាយឆ្លងឆ្លើយ ជាដដែលៗ ដោយប្រើពាក្យ និង ឃ្លាជារបៀបត្រឹមត្រូវ ។

**ការឆ្លើយតបមេរៀនបង្ហាត់** នៅក្នុងកម្មវិធីរៀននៅពេលអាយុតូច និង កម្មវិធីផ្សេងៗ គឺជួយបំរុងសិស្សអោយបានទទួលជោគជ័យនៅពេលផ្លាស់ចូលរៀនថ្នាក់មត្តេយ្យ ។ អ្វីប្រើសំរាប់ស្ទង់វាស់សមត្ថភាពនៃសិស្សត្រូវបានដកស្រង់ពីលទ្ធផលនៃការស្រាវ ជ្រាវ ហើយគ្រូបង្រៀនបន្តការឃ្លាំមើលអំពីភាពលូតលាស់នៃសិស្សម្នាក់ៗ ។



## កម្មវិធីរៀននៅពេលអាយុតូចនៃក្រសួងអប់រំ LBUSD

### Child Development Centers - មណ្ឌលបណ្តុះបណ្តាលកុមារ

**Cynthia Young**, នាយកគ្រប់គ្រង

មណ្ឌលបណ្តុះបណ្តាលកុមារបើកផ្តល់កម្មវិធីដោយយកតំលៃ ឬ មិនយកតំលៃ និង តំលៃ ទាបសំរាប់ទទួលក្រុមគ្រួសារ ដែលមានសិស្ស ព្រីស្គូល ហើយកម្មវិធីបើកផ្តល់ គឺមានជា ពាក់កណ្តាលថ្ងៃ ឬ ពេញថ្ងៃពេញមួយឆ្នាំចំពោះកុមារមានអាយុ បី ទៅ បួន ឆ្នាំ ។ កម្មវិធី នេះជឿជាក់ថា តាមរយៈរៀនតាំងពីអាយុតូចមក គឺសិស្សនឹងរៀនបានល្អដោយចេះកាន់ ភ្ជាប់ជំនឿ និង ជំរៅទឹកចិត្តខ្ពស់ ។ នៅតាមថ្នាក់ គឺមានភាពសង្កត់មកលើការរៀនសំគាល់ និង ការរៀបចំច្បាស់លាស់ ។ មេរៀនត្រូវបានរៀបចំឡើងស្របអាយុកុមារ ដែលបង្ហាត់អំពី ការប្រើភាសា ពាក្យ និង ចំណេះផ្សេងៗតាមចំណង់ចិត្ត និង ទាក់ទងការលើកស្ទួយផ្នែកផ្លូវ ចិត្ត ចំណេះគិត សមត្ថភាពប្រើកំឡាំង និង សុខភាពទូទៅ ។ ដៃគូជាមួយកម្មវិធីរបស់ យើង គឺមានជាផ្ទះ និង សហគមន៍ ដែលបង្ហាញការគាំទ្រ និង សេចក្តីគោរពអំពីភាសា និង ប្រពៃណីរបស់សិស្សសំរាប់ជួយបង្កើនទឹកចិត្តកាន់តែខ្ពស់ដល់ពួកគេ ។ គ្រូបង្រៀនរបស់ យើងទទួលការហ្វឹកហ្វឺនចំណេះជាបន្ត ដែលស្របតាមក្បួនវិទ្យាសាស្រ្តស្រាវជ្រាវយ៉ាងស័ក្ត សិទ្ធ ។ គ្រូបង្រៀន គឺសុទ្ធតែមានសមត្ថភាពខ្ពស់ និង មានសញ្ញាប័ត្របង្ហាត់ត្រឹមត្រូវចេញ ពីរដ្ឋ កាលីហ្វ័រញ៉ា ។

### Educare Los Angeles នៅ Long Beach

**Maria Harris**, នាយកសាលារៀន

Educare បានបង្កើតឡើងតាមរយៈដៃគូសាធារណៈ និង ឯកជនរវាង Head Start/Early Head Start, State Preschool, Long Beach Unified, LA Chamber of Commerce ជំនួយថវិការឯកជន កុមារ ក្រុមគ្រួសារ សហគមន៍ និង បុគ្គលិក ។ ដៃគូដ៏ចំណាប់នេះ ហើយ គឺបានតាំងចិត្តជួយចុះឈ្មោះសិស្ស និង ក្រុមគ្រួសាររបស់ពួកគេទាំងអស់ចូលរៀន នៅក្នុងកម្មវិធី ដែលមានគុណភាពខ្ពស់ ផ្តើមនៅពេលកុមារមានកំណើតភ្លាម រហូតដល់ ពេលចូលរៀនថ្នាក់មត្តេយ្យ ។ ក្នុងនាមជាសាលារៀន ដែលមានបន្ទប់ពិសោធ គឺ Educare ផ្តល់បទពិសោធជាគុណភាពខ្ពស់ និង ជំនួយយ៉ាងពិសេសទៅកាន់កុមារអាយុ 0-5 ឆ្នាំ ។

### Buffum Total Learning Center

**Miriam Garcia**, នាយកសាលារៀន

Buffum Total Learning Center ផ្តល់កម្មវិធីស្របអាយុកុមារ ព្រីស្គូល ដែលត្រូវការជំនួយ ពិសេសអំពីផ្នែកអប់រំអាកប្បកិរិយា បង្ហាត់ភាសា និង ការលេងត្រូវរបៀប ។ Buffum TLC មានជំនួយសំរាប់សិស្សពិការផ្នែកស្តាប់ និង រូបកាយ និង សិស្សមាន បញ្ហាផ្នែកប្រើភាសាគ្រប់កំរិត រួមទាំងសិស្សមានបញ្ហាផ្នែកអាកប្ប កិរិយាពិសេសម្យ៉ាងផង ។ គោលដៅនៃ Buffum TLC គឺជួយសិស្ស ដែលមាន បញ្ហាពិសេសទទួលការព្រាងទុកសំរាប់ចូលរៀនថ្នាក់មត្តេយ្យ និង កំរិតថ្នាក់កាន់តែខ្ពស់ ។

### Head Start/Early Head Start

**Dr. Claudia Sosa-Valderrama**, នាយកគ្រប់គ្រង

កម្មវិធី LBUSD Head Start និង Early Head Start ផ្តល់ជំនួយរៀន និង បីបាច់ ដែលមានគុណភាពខ្ពស់ ដោយមិនបង់តំលៃទៅកាន់កុមារតាំងពីពេលមានកំណើត ភ្លាម រហូតដល់អាយុ ប្រាំ ឆ្នាំ និង ស្រ្តីមានផ្ទៃពោះ ។ កម្មវិធីនេះផ្តល់ជំនួយបីបាច់ ពាក់កណ្តាលថ្ងៃ និង ពេញថ្ងៃសំរាប់សិស្ស ព្រីស្គូល និង កុមារតូចៗ និង បើចាំបាច់ គឺទៅពិនិត្យដល់ផ្ទះ ដើម្បីជួយតាមសេចក្តីត្រូវការរបស់ក្រុមគ្រួសារអំពីផ្នែករៀន និង ការបីបាច់ ។ កម្មវិធី Head Start និង Early Head Start ជួយ សិស្សទទួល ជោគជ័យនៅតាមសាលារៀន និង សំរាប់ជីវិតអំពីផ្នែកបណ្តុះរូបកាយ ចំណេះគិត និង ទឹកចិត្ត ដោយនៅពេលជាមួយគ្នា គឺជួយបង្ហាញក្រុម គ្រួសារអំពីការបង្កើនជំនឿទុកចិត្តក្នុងខ្លួនតាមរយៈការបញ្ចេញមតិ និង ការចូលរួមចំណែកជាមួយកម្មវិធីនៅសាលារៀន ។ សិស្សមិនចាំតែចេះ ប្រើបង្គន់ខ្លួនឯងទេ ទើបអាចចុះឈ្មោះបាន ។ កម្មវិធី Head Start ទទួលយកមុនគេអំពីក្រុមគ្រួសារណាកំពុងមានបញ្ហាពិសេស ដែលនឹង ជួយ សិស្សរបស់ពួកគេជាប្រយោជន៍ច្រើន ។ ក្រុមគ្រួសារ ដែលមានសិទ្ធិ ចូលរួមក្នុងកម្មវិធី គឺត្រូវរស់នៅទីក្រុង Long Beach ឬ Signal Hill ។

### Transitional Kindergarten (TK) - ថ្នាក់រៀន មុនពេលចូលថ្នាក់មត្តេយ្យ

អនុអគ្គនាយកប្រចាំការិយាល័យបឋមសិក្សានៃក្រសួងអប់រំ ឌីស្រ្ទីគ
562.997.8247

Transitional Kindergarten គឺជាថ្នាក់រៀនពេញមួយឆ្នាំក្នុងរយៈពេល ពីរ ឆ្នាំសំរាប់ សិស្សមានកំណើតនៅថ្ងៃទី2 ខែកញ្ញា និង ថ្ងៃទី2 ខែធ្នូ ។ ថ្នាក់នេះមានមេរៀនបង្ហាត់ ស្របអាយុសិស្ស និង គ្រូបង្រៀនស្របច្បាប់ ។ Transitional Kindergarten បើក បង្ហាត់សិស្សជាកំរិតរវាងថ្នាក់ ព្រីស្គូល និង មត្តេយ្យ ។ ថ្នាក់បើកទទួល នៅច្រើនកន្លែង ហើយមានចំនួនគ្រូម្នាក់ទល់នឹងសិស្ស ម្ភៃប្រាំនាក់ ។ សិស្សរៀនភាគច្រើនគឺមានថ្ងៃខែកំណើតក្នុងរដូវស្លឹកឈើធ្លាក់ ។

### Early Transitional Kindergarten -

អនុអគ្គនាយកប្រចាំការិយាល័យបឋមសិក្សានៃក្រសួងអប់រំ ឌីស្រ្ទីគ
562.997.8247

ថ្នាក់ LBUSD Early Transitional Kindergarten (ETK) សព្វថ្ងៃ បើកទទួលនៅ តាមសាលារៀនជំរើសក្នុងក្រសួងអប់រំ ឌីស្រ្ទីគ ។ ថ្នាក់ ETK គឺសំរាប់សិស្ស ចូលអាយុ ប្រាំ ឆ្នាំ បន្ទាប់ពីថ្ងៃខែ ដែលអាចចូលរៀនថ្នាក់ TK បាន ។ សិស្ស ត្រូវមានអាយុ ប្រាំ ឆ្នាំនៅពេលក្នុងឆ្នាំសិក្សាកំពុងតែរៀន ។

ក្រសួងអប់រំ ឌីស្រ្ទីគ Long Beach ជាប់ឈ្មោះល្បីល្បាញក្នុងនាមជាប្រព័ន្ធសាលារៀនមួយដ៏ពិសេសនៅក្នុងសហរដ្ឋ ដោយបានឈ្នះរង្វាន់ជាតិ និង អន្តរជាតិជា គំរូសំរាប់គុណភាពខ្ពស់ ។ គុណភាពខ្ពស់ទាំងអស់នេះក៏បានផ្តល់បន្តមកកាន់ការរៀបចំប្រព័ន្ធជួយកុមាររបស់យើងតាមរយៈកម្មវិធី Early Learning ។